**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ៥៤៩៣ អយក.ហវ

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤

## ជម្រាបជូន

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពថវិកាថ្នាក់កណ្តាល**
**- លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

កម្មវត្ថុ៖ សំណើសុំពន្លឿនការទូទាត់ថវិកាកម្មវិធីពេញលេញរបស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអនុវត្តថវិកាក្នុងឆ្នាំ២០២៤។

យោង៖ សារាចរណែនាំលេខ ០១១ សហវ.សរ.អថ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធាន** ជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញចាប់តាំងពីឆ្នាំ២០១៥មកម្ល៉េះ ហើយមានអង្គភាពថវិកាចំនួន៥៧ (រដ្ឋបាលកណ្តាលចំនួន៣២ និងមន្ទីរ រាជធានី ខេត្តចំនួន២៥) និងកម្មវិធីចំនួន៥ ព្រមទាំងបានវិមជ្ឈការការគ្រប់គ្រងហិរញ្ញវត្ថុជូនអង្គភាពថវិកាក្នុងគោលបំណងផ្តល់ប្រតិភូកម្មសិទ្ធិអំណាចជូនអង្គភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ឱ្យប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព សម្រាប់ការអនុវត្តថវិកាតាមរយៈការប្រគល់អាណត្តិកិច្ចច្បាស់លាស់។ ទន្ទឹមនឹងនេះ ក្រសួងបានពង្រឹងសមត្ថភាពបន្ថែមជូនថ្នាក់ដឹកនាំនិងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុឱ្យយល់ដឹងកាន់តែស៊ីជម្រៅស្តីពីការរៀបចំថវិកា ការអនុវត្តថវិកា និងការពិនិត្យតាមដាននិងវាយតម្លៃ ព្រមទាំងបានបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) ជូនដល់អង្គភាពប្រើប្រាស់។

ក្រសួងបានពិនិត្យឃើញថា គិតត្រឹមថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤ ការអនុវត្តថវិការបស់ក្រសួងសរុបចំនួន៦២.៧% បើធៀបនឹងឥណទានកែតម្រូវ ក្នុងនោះរដ្ឋបាលកណ្តាលចំនួន៣៦.៨% និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តចំនួន៧០.២% ទាបជាងឆ្នាំ២០២៣ ដែលជាបច្ច័យមួយធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ផែនការសកម្មភាពនិងសូចនាករគោលដៅរបស់ក្រសួង។ ក្នុងន័យនេះ ដើម្បីចូលរួមពង្រឹងនិងពន្លឿនការអនុវត្តថវិកាឆ្នាំ២០២៤ ឱ្យកាន់តែមានភាពប្រសើរនិងទាន់ពេលវេលា ហើយស្របជាមួយច្បាប់គតិយុត្ត ក្រសួងស្នើសុំកំណត់៖

១- ប្រធានកម្មវិធី ប្រធានអង្គភាពថវិកានៅថ្នាក់រដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រោមឱវាទក្រសួង ត្រូវចូលរួមជំរុញនិងពន្លឿនរាល់ប្រតិបត្តិការនៃការអនុវត្តថវិកាឱ្យស្របតាមក្របខណ្ឌពេលវេលានិងផែនការសកម្មភាព ព្រមទាំងស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាននិងសារាចរណែនាំលេខ០១១ សហវ.សរ.អថ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាកំហិត។

២- ការបោះផ្សាយអាណត្តិបើកប្រាក់ និង/ឬអាណត្តិនិយ័តកម្មគ្រប់ប្រភេទចុងក្រោយបង្អស់ដែលបានចុះហត្ថលេខាអាណាប័កដើមខ្សែ ត្រូវបញ្ជូនមកនាយកដ្ឋានហិរញ្ញវត្ថុយ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែធ្នូ ឆ្នាំ២០២៤ ដើម្បីឆ្លងការឯកភាពក្នុងប្រព័ន្ធព័ត៌មានវិទ្យា (FMIS) រីឯអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ក៏ត្រូវបញ្ជូនយ៉ាងយូរ ត្រឹមដើមសប្តាហ៍ទី៣ នៃខែធ្នូ ឆ្នាំ២០២៤ ដល់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា។ ដោយឡែកក្នុងករណីអង្គភាពថវិកាបោះផ្សាយអាណត្តិបើកប្រាក់ និង/ឬអាណត្តិនិយ័តកម្ម មិនមានឯកសារគតិយុត្តភ្ជាប់មកជាមួយគ្រប់គ្រាន់ ត្រឹមត្រូវ និងច្បាស់លាស់ នោះក្រសួងនឹងមិនឯកភាពផ្តល់ជូនតាមសំណើ សម្រាប់អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល។

៣- ក្នុងករណីការបោះផ្សាយអាណត្តិបើកប្រាក់និង/ឬអាណត្តិនិយ័តកម្មចុងក្រោយបង្អស់របស់អង្គភាពថវិកាមិនទាន់ពេលដូចនឹងចំណុចទី២ខាងលើ ក្រសួងនឹងមិនអនុញ្ញាតឱ្យដំណើរការក្នុងប្រព័ន្ធព័ត៌មានវិទ្យា (FMIS) ដោយតម្រូវឱ្យប្រើប្រាស់ឥណទានថវិកានៅឆ្នាំបន្ទាប់គឺឆ្នាំ(N+1) ដើម្បីទូទាត់ការចំណាយនេះសម្រាប់អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល។

៤- គ្រប់ប្រធានអង្គភាព ត្រូវចូលរួមជំរុញការប្រើប្រាស់ប្រព័ន្ធ EFMS តាមស្មារតីនៃលិខិតលេខ៤៣១០ អយក.ហវ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ លើមុខងារមានជាអាទិ៍៖ វិភាជថវិកា (BA) បញ្ជាទិញ(PO) គណនីត្រូវសង(AP) និងរបាយការណ៍ ដើម្បីពង្រឹងការកត់ត្រាទិន្នន័យ ឱ្យស្របតាមការអនុវត្តសកម្មភាពជាក់ស្តែងរបស់អង្គភាពសាមី ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធFMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាបច្ច័យយ៉ាងល្អសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពខ្ពស់។

៥- គ្រប់ប្រធានអង្គភាព ត្រូវប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវភាពជាម្ចាស់ក្នុងការពិនិត្យតាមដាន និងចូលរួមយ៉ាងសកម្មនូវការអនុវត្តថវិកាឱ្យទាន់ពេលវេលា និងត្រឹមត្រូវ ដើម្បីធានាស្ថិរភាព និងចីរភាពនៃតុល្យភាពចំណាយ ក៏ដូចជាលើកកម្ពស់សុខុមាលភាពការងាររបស់អង្គភាពសាមី។

៦- នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួង ក្នុងករណីមានបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តថវិកា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធាន** មេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គលេខាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ